**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**ជំនួបពិភាក្សាជាមួយក្រុមជំនាញការនៃធនាគារអភិវឌ្ឍន៍អាស៊ី** ADB



ភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០១៦៖ **ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម** បានជួបពិភាក្សាជាមួយក្រុមជំនាញការនៃធនាគារអភិវឌ្ឍន៍អាស៊ី ADB នាព្រឹកថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ដែលផ្តោតជាសំខាន់ ទៅលើដំណើរការរៀបចំគម្រោងសាកល្បងតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន(PPP) យោងតាមឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន

រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន

(PPP) សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០ **ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** បានស្នើគម្រោងមួយចំនួន ដល់ធនាគារ ADB ដើម្បីពិនិត្យពិចារណា ក្នុងការសិក្សាពីសមិទ្ធិលទ្ធភាព ។ ក្នុងនោះរួមមានគម្រោងបង្កើត តំបន់កម្រងចង្កោមសហគ្រាសខ្នាតតូចនិងមធ្យម ( SMEs Cluster Zone) ដើម្បីពន្លឿនការអភិវឌ្ឍន៍វិស័យសហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជា ដោយកំណត់នូវទីតាំងមួយដែលមានសក្តានុពលផ្នែកសេដ្ឋកិច្ច ។ ករណីនេះរដ្ឋអាចជាភាគីទទួលបន្ទុក ផ្នែក ដីធ្លី ដើម្បីចូលរួមជាមួយវិស័យ ឯកជន ។ និងគម្រោងមួយទៀត គឺគម្រោងផ្គត់ផ្គង់ទឹកស្អាត នៅខេត្តជាប់តំបន់ឆ្នេរ គឺ ខេត្តកំពត និងខេត្ត កែប ដោយយកទឹកពីទំនប់វារី អគ្គិសនី នៅកំចាយ ខេត្តកំពត ។ ក្នុងផែនការនេះដែរបានគិតគូរបន្ថែមនូវគម្រោងមួយចំនួនទៀតលើទីតាំងដីបម្រុងរបស់ខេត្ត កែប ដូចជាការបង្កើត សួនបំពាក់ផ្ទាំងសូឡាអគ្គិសនី ដើម្បីផ្គត់ផ្គង់ដំណើរការរោងចក្រទឹកស្អាតនៅទីនោះនិងសេចក្តីត្រូវការក្នុងខេត្ត និងបង្កើតវិទ្យាស្ថានបណ្តុះបណ្តាលវិស័យទឹកស្អាតក៏ដូចជាបង្កើតឲ្យមានសាកលវិទ្យាល័យក្នុងខេត្តផងដែរ។

លោក Pratyush P.Prashant តំណាង ADB បានបញ្ជាក់ថា៖ ឯកសារគោលនយោបាយ ស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន(PPP) សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០ ត្រូវបានចុះហត្ថលេខារួចហើយដោយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦ ។ ដូចមានចែងក្នុងឯកសារគោលនយោបាយនេះ វិធានការចំពោះ មុខមួយចំនួនក្នុងចំណោមវិធានការផ្សេងទៀតគឺដាក់ឲ្យអនុវត្តគម្រោងសាកល្បងចំនួន ២ រឺ ៣ គម្រោង ដែលមានរយៈពេលមធ្យមពី ០៦ ខែ ទៅ ០៩ ខែ តាមយន្តការ PPP ។ គម្រោងសាកល្បងនេះ នឹងត្រូវជ្រើសរើសចេញពីវិស័យអាទិភាពរបស់រាជរដ្ឋាភិបាលតែប៉ុណ្ណោះ ។ រីឯដំណើរការរៀបចំគម្រោងសាកល្បងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានទទួលជំនួយបច្ចេកទេស ពី ADBផងដែរ។

ជាចុងក្រោយ ADB បានបង្ហាញនូវជំហរគាំទ្រ និងរួមចំណែកដល់ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចនៅកម្ពុជា និងសហការជានិច្ច ក្នុងការផ្តល់ជំនួយបច្ចេកទេស និងប្រឹក្សាយោបល់ ។ ក្នុងនោះដៃគូសន្ទនា បានសន្យានឹងជួបពិភាក្សាគ្នាជា បន្តបន្ទាប់ទៀត ជាពិសេសពេលដែលការរៀបចំឯកសារក្របខ័ណ្ឌគតិយុត្តរបស់ ADB បានរួចរាល់ហើយ ។



រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន